# ស្ថានភាព ស្រូវអង្ករសំរាប់ឆ្នាំ ២០០៩

**ដោយបណ្ឌិត យ៉ង សាំងកុមារ និងលោក រិន ប្រេត**

**អង្គការសេដាក, ថ្ងៃទី ២១ ខែមករា ឆ្នាំ ២០០៩**

សេដាក បានធ្វើការតាមដានស្ថានភាពតំលៃអង្ករចាប់តាំងពីដើមឆ្នាំ ២០០៨ ក្នុងគោលបំណងដើម្បីផ្តល់នូវពត៌មានគួរអោយទុកចិត្តបានសំរាប់ផ្នែកទីផ្សារនៃអង្គការសេដាក ក្នុងការកំណត់តំលៃស្រូវ និងអង្ករ ។ យើងមានគោលបំណងផ្តល់ពត៌មានដល់ក្រុមអ្នកផលិត និងអ្នកពាក់ពន្ធ័ដទៃទៀត ព្រមទាំងក្រុមអតិថិជនអំពីស្ថានភាពស្រូវ និងតំលៃរបស់វា ។ នៅក្នុងឆ្នាំ ២០០៩ យើងចង់បង្កើតនូវរបាយការណ៍ស្ថានភាពអង្ករទាំងនៅលើទីផ្សារក្នុងស្រុក និងទីផ្សារអន្តរជាតិជាប្រចាំខែ។

ចាប់តាំងពីការប្រមូលផលឆ្នាំ ២០០៧-២០០៨ កន្លងមក តំលៃស្រូវអង្ករកើនឡើងយ៉ាងគំហុក ។ នេះជាលើកទីមួយហើយ ដែលតំលៃស្រូវកើនឡើងគួរអោយកត់សំគាល់បន្ទាប់ពីរយៈពេលប៉ុន្មានឆ្នាំ ដែលតំលៃស្រូវស្ថិតនៅនឹងថ្កល់ ឬក៏ធ្លាក់ចុះបើធៀប នឹងកំរិតអតិផរណា។

រយៈពេលជាច្រើនឆ្នាំកន្លងមក ប្រជាជននៅលើពិភពលោកបានទទួលទានអង្ករច្រើនជាងការផលិត ។ ដូច្នេះធ្វើអោយបរិមាណស្រូវនៅក្នុងស្តុកធ្លាក់ចុះក្នុងកំរិតមួយទាបគួរអោយព្រួយបារម្ភ។

បញ្ហានេះធ្វើអោយមានការព្រួយបារម្ភអំពីសន្តិសុខស្បៀង ដែលធ្វើអោយឈ្មួញឆ្លៀតឱកាសបង្កើនតំលៃទ្វេដង ក្នុងរយៈពេលតែពីរបីខែប៉ុណ្ណោះ។ ចាប់តាំងពីខែមេសា និងឧសភា មក តំលៃស្រូវ អង្ករ ចាប់ផ្តើមធ្លាក់ចុះវិញជាបន្តបន្ទាប់។ តាមការបង្ហាញនៅក្នុងក្រាហ្វិកខាងក្រោមតំលៃអង្ករនៅចុងឆ្នាំ ២០០៨ ខ្ពស់ជាងតំលៃអង្ករកាលពីឆ្នាំកន្លងទៅពី ៥០ ទៅ ៦០ ភាគរយ ។



នៅពេលដែលតំលៃអង្ករធ្លាក់ចុះជាបន្តបន្ទាប់ក្នុងកំឡុងពេលបួនខែចុងក្រោយនៃឆ្នាំ ២០០៨ នេះ វានៅមានភាពស្រពិចស្រពិលថាតើតំលៃស្រូវ អង្ករ នឹងនៅតែបន្តធ្លាក់ចុះនៅក្នុងកំឡុងពេល និងក្រោយពេលច្រូតកាត់ (ខែវិច្ឆិកា រហូតដល់ខែមករា) ថ្មីៗនេះដែរឬយ៉ាងណា? ទោះបីយ៉ាងណាក៏ដោយតំលៃស្រូវទិញពីកសិករកើនឡើងសន្សឹមៗ ក្នុងអំឡុងពេលច្រូតកាត់ឆ្នាំនេះ ដោយសារតែការប្រកួតប្រជែងជាមួយឈ្មួញមកពីវៀតណាម និងភ្នាក់ងាររបស់ពួកគេចាប់តាំងពីដើមខែធ្នូកន្លងទៅថ្មីៗ នេះ។

នៅលើទីផ្សារក្នុងស្រុកវិញ តំលៃអង្ករបានធ្លាក់ចុះសន្សឹមៗក្នុងអំឡុងពេលប៉ុន្មានសប្តាហ៍ថ្មីៗនេះ ប៉ុន្តែនេះជាបម្រែបម្រួលប្រចាំឆ្នាំ ។ នៅពេលដែលរដូវច្រូតកាត់ថ្មីមកដល់តម្លៃស្រូវ អង្ករ ហាក់ដូចជាធ្លាក់ចុះបន្តិច ជាពិសេសនៅក្នុងឆ្នាំដែលទិន្នផលស្រូវប្រមូលបានច្រើន ។ ទោះបីយ៉ាងណាក៏ដោយ នៅក្នុងករិតណាមួយនោះទីផ្សារស្រូវ អង្ករនៅក្នុងទីក្រុងភ្នំពេញប្រែប្រួលទៅតាមទីផ្សារនៅប្រទេសថៃ ។ ដូចជានៅក្នុងកំឡុងពេលប៉ុន្មានខែថ្មីៗនេះ តំលៃអង្ករនៅប្រទេសថៃធ្លាក់ចុះយ៉ាងលឿន។

ផ្នែកតាមក្រាហ្វិក និងតារាងខាងក្រោមបង្ហាញថាតំលៃអង្ករនៅប្រទេសថៃ ហាក់ដូចជាថេរបើធៀបនឹងបម្រែ-បម្រួលនៃ អត្រាប្តូរប្រាក់។

## សមាគមអ្នកនាំអង្ករចេញរបស់ថៃ

## សន្ទស្សន៍តំលៃស្រូវ (គិតជាដុល្លារក្នុង ១ តោន)

| ប្រភេទអង្ករ | 21 មករា 09 | 7 ធ្នូ 08 | 24 ធ្នូ 08 | 11 ធ្នូ 08 | 26 វិច្ឆិកា 08 |
|---|---|---|---|---|---|
| អង្ករ ហូមម្លិះថៃករិតលេខ១ (2008/09) | $902 | $854 | $837 | $807 | $818 |
| អង្ករ Pathumthani Fragrant ថៃ | $767 | $733 | $730 | $717 | $714 |
| អង្ករ White Rice 100% ថៃករិតលេខ២ | $623 | $590 | $585 | $574 | $586 |
| អង្ករ White Rice 5% ថៃ | $592 | $560 | $569 | $559 | $571 |

ប្រទេសផលិតស្រូវជាច្រើននៅលើពិភពលោក ទទួលបានទិន្នផលស្រូវនៅក្នុងឆ្នាំនេះខ្ពស់ជាងឆ្នាំ ២០០៧ ហើយប្រទេសដែលនាំចូលស្រូវខ្លះដែលបាននាំចូលស្រូវកាលពីឆ្នាំទៅមិញអាចនឹងមិននាំស្រូវចូលទៀតទេឆ្នាំនេះ ដូចជាប្រទេសឥណ្ឌូនេស៊ី ជាដើម ។ ទោះបីយ៉ាងណាក៏ដោយ ក៏មានប្រទេសជាច្រើននឹងនាំចូលស្រូវដើម្បីកែលំអបរិមាណស្រូវក្នុងស្តុករបស់គេដែលកាលពីពីរ-បីឆ្នាំកន្លងទៅដែល បរិមាណស្រូវក្នុងស្តុករបស់ពួកគេបានធ្លាក់ដល់ករិតមួយទាបគួរអោយព្រួយបារម្ភ។ បើតាមទស្សនៈ របស់អង្គការ កសិកម្ម និងស្បៀងអាហារពិភពលោក (FAO)៖ ការវិភាគទីផ្សារស្រូវអង្ករ

នៅលើពិភពលោកបានប៉ាន់ប្រមាណថា បរិមាណអង្ករទទួលទានសំរាប់មនុស្សម្នាក់មានការកើនឡើងបើធៀបឆ្នាំកន្លងទៅ។ សំរាប់ពិត័មានលំអិតសូមមើលតារាង ខាងក្រោម៖

# ទីផ្សារស្រូវ អង្ករនៅលើពិភពលោក

| | | 2006/07 | 2007/08 | 2008/09 | បម្រែបម្រួលរវាងឆ្នាំ 2007/08 និង 2008/09 |
|---|---|---|---|---|---|
| | | **គិតជាលានតោន** | | | **គិតជាភាគរយ** (%) |
| **តុល្យការនៅលើពិភពលោក** | | | | | |
| ផលិតកម្ម | | **428.7** | **439.5** | **450.2** | **2.4** |
| ពាណិជ្ជកម្ម | | **32.3** | **31.0** | **30.5** | **-1.6** |
| បរិមាណប្រើប្រាស់សរុប | | **427.1** | **436.5** | **444.4** | **1.8** |
| បរិមាណសំរាប់មនុស្សទទួលទាន | | 372.2 | 377.4 | 384.2 | 1.8 |
| បរិមាណសល់នៅក្នុងស្តុក | | **104.6** | **109.3** | **115.4** | **5.5** |
| | | | | | |
| **តំរូវការ និងការផ្គត់ផ្គង់** | | | | | |
| តំរូវការសំរាប់មនុស្សម្នាក់ | | | | | |
| ពិភពលោក | គ.ក/ឆ្នាំ | 56.9 | 56.7 | 57.0 | 0.5 |
| ប្រទេសក្រីក្រ | គ.ក/ឆ្នាំ | 69.6 | 69.6 | 70.0 | 0.6 |
| អត្រាភាគរយនៃបរិមាណសល់ក្នុងស្តុកធៀបនឹងបរិមាណប្រើប្រាស់សរុប | % | 24.0 | 24.6 | 25.5 | 3.8 |
| អត្រាបាត់បង់ក្នុងពេលដឹកជញ្ជូន និងពេលរក្សាទុកក្នុងឃ្លាំង | % | 15.4 | 17.1 | 18.6 | 8.8 |
| | | 2006 | 2007 | 2008 | បម្រែបម្រួល៖ មករា-តុលា ២០០៨ |

| | | | | | ធៀបនឹង<br>មករា-តុលា ២០០៧ |
|---|---|---|---|---|---|
| | | | | | % |
| FAO (សន្ទស្សន៍តំលៃ)<br>(1998-2000=100) | | 117 | 137 | 258* | 94 |

នៅក្នុងប្រទេសកម្ពុជា ទោះបីជាភាពរាំងស្ងួតអូសបន្លាយពេលវេលាយូរ តែទិន្នផលស្រូវរំពឹងទុកសំរាប់ឆ្នាំ ២០០៨ នេះ មានភាពប្រហាក់ប្រហែលឬលើសឆ្នាំ ២០០៧ បន្តិចបន្តួច។ ស្ថានភាពផលិតកម្មស្រូវរដូវប្រាំងអាចមានលក្ខណៈប្រសើរជាងឆ្នាំ ២០០៧ /០៨ ដោយសារតែការពង្រីកផ្ទៃដីដាំដុះ និងតំលៃប្រេងសាំងធ្លាក់ចុះ។

ទោះបីយ៉ាងណាក៏ដោយ កសិករមានការខកចិត្តចំពោះតំលៃស្រូវធម្មតាមានការធ្លាក់ចុះយ៉ាងគំហុកពី ១១០០ ទៅ ១៣០០ រៀលក្នុង ១ គីឡូក្រាម នៅក្នុងខែសីហា និងខែកញ្ញាមកត្រឹមតំលៃ ៦០០ ទៅ ៧០០ រៀលក្នុង ១ គីឡូក្រាម នៅក្នុងខែ ធ្នូ ២០០៨ និងខែមករាឆ្នាំ ២០០៩។ យ៉ាងណាក៏ដោយ តំរូវការស្រូវដែលមានគុណភាពខ្ពស់ (ស្រូវក្រអូប)ដូចជាផ្កាម្លិះ ឬសុម៉ាលី ហាក់ដូចជា កើន ហើយតំលៃរបស់វាក៏ខ្ពស់ផងដែរ នៅជុំវិញតំលៃ ១០០០ ទៅ ១២០០ រៀលក្នុង ១ គីឡូក្រាម។ អង្គការសេដាក បានផ្តល់អោយកសិករនូវតំលៃ ១២៥០ ទៅ ១៣០០ ក្នុង ១ គីឡូក្រាមសំរាប់ស្រូវផ្កាម្លិះ និងសុម៉ាលី ដែលផលិតតាមគោលការណ៍ធម្មជាតិ។

បើតាមការរំពឹងទុកតំលៃអង្ករនឹងកើនឡើងនៅក្នុងខែមិនា សំរាប់ទីផ្សារក្នុងស្រុក ដែលជាការកើនឡើងជាទំលាប់ជារៀងរាល់ឆ្នាំ។ យ៉ាងណាក៏ដោយ វាមិនអាចកើនឡើងខ្លាំងដូចឆ្នាំ ២០០៨ នោះទេ។ បើតាមការប៉ាន់ប្រមាណតំលៃអង្ករដែលមានគុណភាពខ្ពស់ (អង្ករក្រអូប)នឹងកើនឡើងពី ២០ ទៅ ៤០ ភាគរយ ក្នុងខណៈពេលតំលៃអង្ករធម្មតានឹងកើនឡើងពី ១០ ទៅ ៣០ ភាគរយ។